# ជំនឿនិងគុណតម្លៃះ
# ទំនាក់ទំនងរវាងមនុស្សជាតិនិងធម្មជាតិ
# នៅប្រទេសកម្ពុជា





WWF

ANGKOR CENTRE FOR CONSERVATION OF BIODIVERSITY
ACCB
A KINGDOM OF CAMBODIA/GOETZ-PROJECT

ALLWETTERZOO MÜNSTER

WTG
Welttierschutz-gesellschaft e.V.

# ជំនឿនិងគុណតម្លៃ ទំនាក់ទំនងរវាងមនុស្សជាតិនិងធម្មជាតិ
## មគ្គុទ្ទេសក៍សម្រាប់ព្រះសង្ឃពុទ្ធសាសនា នៅប្រទេសកម្ពុជា

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ WWF  និងអង្គការ WTG
ដែលបានចូលរួមឧបត្ថម្ភថវិកាដើម្បីបោះពុម្ពសៀវភៅនេះឡើង

**សៀវភៅនេះរៀបរៀងឡើងដោយៈ**

ប្រែម ស្ទីនហ្វ៊អ៊ីសិន
ជិម សុភាព
វ៉ាន់ សុជា
ហ្សង់តាល់ អែលគីន
គ្រីសតែល ហ្វ្រិហ្វីយ៉ូន



រក្សាសិទ្ធិដោយមជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ និងអង្គការ WWF © ឆ្នាំ២០២១

# មាតិកា


- ផ្នែកទី១ - ព្រះពុទ្ធសាសនានិងធម្មជាតិ..........១
  - ព្រះពុទ្ធ..........២
  - ព្រះធម៌..........៣
    - បញ្ចសីល..........៥
    - សុត្តនិបាត..........៧
    - សម្ដេចព្រះមហាឃោសានន្ទ..........៨
  - ព្រះសង្ឃ..........៩
    - តួនាទីព្រះសង្ឃនៅក្នុងសង្គម..........១០
    - ព្រះពុទ្ធសាសនាចូលរួមនៅក្នុងសង្គម..........១១
    - វត្តនិងវត្តអារាម..........១២

# មាតិកា


- ផ្នែកទី២- ជំនឿតាមបែបប្រពៃណី..........១៤
  - ជំនឿតាមបែបប្រពៃណីនិងវិទ្យាសាស្ត្រ..........១៥
  - ជំនឿតាមបែបប្រពៃណីនៅប្រទេសកម្ពុជា..........១៨
  - ជំនឿអរូបិយ..........១៩
- ផ្នែកទី៣- សត្វជាទីសក្ការបូជា រុក្ខជាតិដ៏ពិសិដ្ឋ តំបន់ស័ក្តិសិទ្ធិ (កន្លែងស័ក្តិសិទ្ធិ)..........២២
  - រុក្ខជាតិនិងដើមឈើដ៏ពិសិដ្ឋ..........២៣
  - សត្វជាទីសក្ការៈបូជា..........២៩
  - តំបន់ធម្មជាតិនិងទឹកស័ក្តិសិទ្ធិ..........៤១
  - ប្រភេទសត្វមួយចំនួនដែលមានអត្ថន័យតាមបែបវប្បធម៌..........៥០
- ផ្នែកទី៤-ការអភិវឌ្ឍន៍នៅប្រទេសកម្ពុជាដើម្បីឲ្យសត្វមានជីវិតទាំងអស់បានគង់វង្សនិងឋិតថេរ..........៦៦

# មាតិកា


- ការអភិរក្ស............................................................................................................................................៦៧
- ការប្រមូលផល ឬ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព.....................................................៧១
- ការការពារធនធានធម្មជាតិ ( ទឹក ដី ខ្យល់ ធម្មជាតិ )...................................................................................៧២
- ការប្រើប្រាស់ភាវៈរស់មានវិញ្ញាណ ( សត្វ ) និងភាវៈរស់គ្មានវិញ្ញាណ (រុក្ខជាតិ ) ពីក្នុងព្រៃ.................................៧៣
- ការទាក់ចាប់សត្វ ការបរបាញ់និងការនេសាទ...............................................................................................៧៤
- ការបំពុល ( បរិស្ថាន )...............................................................................................................................៧៥
- ការកែច្នៃជាថ្មីឡើងវិញ...............................................................................................................................៧៦
- ផ្នែកទី៥- គំរូនៃការអភិរក្សដោយផ្អែកលើព្រះពុទ្ធសាសនា.........................................................................៧៨
- ផ្នែកទី៦- ការធ្វើផែនការសកម្មភាពរួមគ្នាមួយដោយមានការរួម..................................................................៨៧

# ផ្នែកទី១៖ ព្រះពុទ្ធសាសនានិងធម្មជាតិ



គំនូរនៅវត្តប្រាសាទបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប

ព្រៃព្រឹក្សា គឺជាកន្លែង
មនោរម្យ ដែលនៅទីនោះ
មនុស្សសាមញ្ញធម្មតា
ស្វះស្វែងរកមិនឃើញការ
សប្បាយ។
មនុស្សប្រាសចាកតណ្ហានឹង
ត្រេកអរនៅទីនោះ សម្រាប់
មនុស្សទាំងឡាយ ដែលមិន
ស្វែងរកការសប្បាយខាងផ្លូវ
កាមកិលេស។

**ដកស្រង់ពីធម្មបទគាថា**



# ព្រះពុទ្ធ

- ព្រះអង្គទ្រង់ប្រសូតនៅក្រោមដើមសាលព្រឹក្ស។
- ការតាំងសមាធិលើកដំបូងរបស់ព្រះអង្គបានកើតឡើងនៅក្រោមដើមជំពូព្រឹក្ស។
- ព្រះអង្គទ្រង់ត្រាស់ដឹងនៅក្រោមដើមពោធិព្រឹក្ស។
- ការសម្តែងធម៌ទេសនាជាលើកទី១ របស់ព្រះអង្គនៅក្នុងសួនឧទ្យាននៃព្រៃឥសីបតនៈ (សួនឧទ្យានសត្វប្រើស)។
- ព្រះអង្គទ្រង់ចូលព្រះបរិនិព្វាននៅចន្លោះដើមសាលព្រឹក្សទាំងគូ។




Wat Botum Wattey Reacheveraram, Phnom Penh

# ព្រះធម៌

ផលបានកើតឡើងអាស្រ័យហេតុ មានហេតុទើបបាន
មានផល។
ផលនឹងកើតឡើងអាស្រ័យហេតុ មានហេតុទើបនឹង
មានផល។

**ព្រះពុទ្ធ**

ដកស្រង់ពីព្រះសូត្រ



# ព្រះធម៌

- តើអំពើរបស់យើងមានផលប៉ះពាល់បែបណាខ្លះចំពោះបរិស្ថាន ?
- ភាពសុខដុមរមនារវាងគ្រប់ផ្នែកទាំងអស់នៃបរិស្ថាន។
- សេចក្ដីមេត្តានិងការស្រឡាញ់ចំពោះសត្វខុសពីមនុស្ស ប៉ុន្តែមានលក្ខណៈប្រហាក់ប្រហែលគ្នា។ សូមមានសេចក្ដីករុណានិងការគោរពស្រឡាញ់ចំពោះសត្វឲ្យដូចដែលយើងមានចំពោះមនុស្សដែរ។


សិល្បៈសាស្រ្តាស្លឹករឹត (ថៃឡុងដ៏) ស.វ ទី១៩

# បញ្ចសីលៈ
## សិក្ខាបទទាំង ៥ របស់ពុទ្ធសាសនា



# បញ្ចសីលៈ
# សិក្ខាបទទាំង ៥ របស់ពុទ្ធសាសនា

**បកស្រាយអត្ថន័យតាមបែបបទបរិស្ថានៈ**

- មិនសម្លាប់សត្វ(មិនបង្កអន្តរាយដល់អ្នកដទៃ)៖ ទាក់ទងទៅនឹងផលប៉ះពាល់និងការបំពុលបរិស្ថាន
- មិនលួចទ្រព្យគេ៖ ទាក់ទងទៅនឹងសាជីវកម្មទោហនកម្មចំពោះធនធានធម្មជាតិ
- វៀរចាកកាមរាគ ឬ មិនចូលរួមក្នុងសកម្មភាពរំលោភបំពាន៖ ទាក់ទងទៅនឹងការគ្មានមនុស្សធម៌ចំពោះសត្វនិងរុក្ខជាតិ
- មិននិយាយកុហក់បោកប្រាស់គេ៖ ទាក់ទងទៅនឹងសកម្មភាពផ្សព្វផ្សាយ ដើម្បីជំរុញឲ្យមានការនិយមប្រើប្រាស់
- មិនសេពគ្រឿងស្រវឹង (សុរា)៖

# សុត្តនិបាត





**ព្រះពុទ្ធទ្រង់មានពុទ្ធដីកាយ៉ាងដូច្នេះថា៖**

អ្នកស្គាល់តិណជាតិ វល្លិជាតិ រុក្ខជាតិ រួចហើយអ្នកស្គាល់សត្វល្អិតគ្រប់ប្រភេទ ដូចជា ដង្កូវ ពពួកសត្វមមាច ស្រមោចជាដើម។ អ្នកក៏ស្គាល់ពពួកចតុបាទទាំងធំទាំងតូចនិងអបាទកសត្វមាន ពស់ ត្រី ដែលហិចហែលសប្បាយនៅក្នុងទឹក សត្វបក្សាបក្សីដែលមានស្លាប ហើយអាចហោះហើរនៅលើអាកាសបាន....។ អ្នកអាចដឹងលក្ខណៈសម្គាល់របស់ពូជសត្វគ្រប់ប្រភេទ ហើយពូជរបស់វាមានលក្ខណៈផ្សេងៗគ្នាទៀតផង។

**ដកស្រង់ពីសុត្តនិបាត** (ឯកសារដើមរបស់ព្រះពុទ្ធ ដែលនិយាយអំពីតម្លៃនៃការស្គាល់ធម្មជាតិ)

# សម្តេចព្រះមហាឃោសានន្ទ

កាលណាយើងស្រឡាញ់ការពារបរិស្ថាន កាលនោះធម្មជាតិមុខតែល្អចំពោះយើងហើយ។ ដើមឈើទាំងឡាយប្រៀបឧបមាដូចជាមាតាបិតារបស់យើងដូច្នេះដែរ។ ដើមឈើចិញ្ចឹមបីបាច់ថែរក្សាយើងឱ្យធំធាត់ ផ្គត់ផ្គង់ដល់យើងនូវវត្ថុគ្រប់បែបយ៉ាង មានដូចជាផ្លែ ស្លឹក មែក ដើម ជាដើម។ ដើមឈើទាំងនោះផ្តល់ដល់យើងនូវម្ហូបអាហារ និងបំពេញបំណងប្រាថ្នារបស់យើងជាច្រើនទៀត។

ប៉ុន្តែបើយើងកាប់រំលំដើមឈើចោលវានឹងមិនមានភ្លៀងតទៅទៀតទេ។ ដើមឈើធ្វើឱ្យមានភ្លៀងធ្លាក់។ អាស្រ័យហេតុនេះហើយ នៅក្នុងការធ្វើធម្មយាត្រានេះ យើងនឹងផ្សព្វផ្សាយព្រះធម៌អំពីការថែរក្សាការពារខ្លួនយើងនិងការថែរក្សាការពារបរិស្ថានរបស់យើង ដែលនេះជាព្រះធម៌ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើងទាំងអស់គ្នា។

ពេលដែលយើងទទួលស្គាល់ថា យើងគឺជាផ្នែកមួយនៃក្រុមគ្រួសារមនុស្សដែលរស់តាមផ្លូវធម្មជាតិរបស់ព្រះពុទ្ធ បន្ទាប់មកយើងអង្គុយនិយាយដោយសន្តិភាព។

**សម្តេចព្រះមហាឃោសានន្ទ**

# ព្រះសង្ឃ



# តួនាទីព្រះសង្ឃនៅក្នុងសង្គម

មនុស្សនិងព្រៃឈើ មានទំនាក់ទំនងគ្នា។ ប្រសិនបើយើងថែរក្សាខ្លួនយើង នោះយើងនឹងថែរក្សាព្រៃឈើដែរ ហើយព្រៃឈើនឹងថែរក្សាដល់យើងវិញ។

**សម្តេចព្រះមហាឃោសានន្ទ**

- វិន័យបិដក (វគ្គ១)
- ចូលវស្សា
- ព្រះពុទ្ធសាសនាចូលរួមនៅក្នុងសង្គម



# ព្រះពុទ្ធសាសនាចូលរួម នៅក្នុងសង្គម




យើងជាពុទ្ធសាសនិក ត្រូវស្វែងរកសេចក្តីក្លាហានដោយចេញពីវត្តរបស់យើង ហើយចូលទៅកាន់ពិសោធន៍មួយទៀតនៃមនុស្សជាតិ គឺវត្តពោរពេញទៅដោយសេចក្តីទុក្ខ។ ការធ្វើបែបនេះនឹងអាចធ្វើការផ្លាស់ប្តូរម្តងបន្តិច ចំពោះមនុស្សនៅទូទាំងទ្វីបអាស៊ី បានរៀនសូត្រដោយពឹងផ្អែកទៅលើការបួសជាព្រះសង្ឃតាមទំនៀមទំលាប់។ ប្រជាជនកម្ពុជាជាច្រើនបានប្រាប់ខ្ញុំថា "ព្រះតេជព្រះគុណ ជាសង្ឃត្រូវគង់នៅក្នុងវត្ត"។ វាមានការពិបាកសម្រាប់ពួកគេក្នុងការសម្របខ្លួនទៅនឹងតួនាទីថ្មីនេះ ប៉ុន្តែយើងជាព្រះសង្ឃត្រូវតែឆ្លើយតបទៅនឹងសម្រែកទ្រហោយំកាន់តែខ្លាំងឡើងៗនៃសេចក្បីទុក្ខលំបាក។ យើងគ្រាន់តែចងចាំថា វត្តរបស់យើងគឺនៅជាមួយយើងជានិច្ច។ យើងគឺជាវត្តរបស់យើង។

**សម្តេចព្រះមហាឃោសានន្ទ** (ឆ្នាំ១៩៩២)

# វត្តនិងវត្តអារាម



# វត្តនិងវត្តអារាម



- វត្តជាទីប្រជុំនៃប្រជាសហគមន៍។ វត្តមានតួនាទី ផ្ដល់ការអប់រំនិងជាកន្លែងគំរូ។
  - ព្រះសម្មាសម្ពុទ្ធទ្រង់បានលើកទឹកចិត្តដល់អ្នកមានសទ្ធាជ្រះថ្លារបស់ព្រះអង្គឱ្យចេះសាងសង់វត្តអារាមនៅត្រង់ទីណាដែលប្រកបដោយទេសភាពធម្មជាតិ។ ឧទាហរណ៍: វត្តវេឡុវនារាម (វិហារព្រៃឫស្សី)។
  - ពាក្យបាលីថា " វិហារ" សំដៅដល់វិហារព្រះពុទ្ធសាសនា = កន្លែងល្ហល្ហេវ ឬ កណ្ដាលវាល តាំងនៅក្នុងព្រៃ (ភាសាបាលី)។
- វត្តអារាមនៅប្រទេសកម្ពុជាច្រើនសាងសង់ឡើងនៅតាមមាត់ទន្លេ ឬ ស្ទឹង
- ទំនៀមទំលាប់ខ្មែរបែបព្រះពុទ្ធសាសនាតាំងពីរជ្ជកាលព្រះបាទស៊ីសុវត្ថិ: ការដាំដើមគគីនៅក្នុងបរិវេណវត្ត



# ផ្នែកទី២- ជំនឿតាមបែបប្រពៃណី



ព្រះសម្មាសម្ពុទ្ធទ្រង់បានសង្កត់ធ្ងន់
លើការនៅរួមរស់ជាមួយគ្នាដោយ
សហវិជ្ជមានជាមួយសាសនា
និងជំនឿទាំងឡាយដទៃផ្សេងទៀត។

ដរាបណាមនុស្សនៅតែគោរពលើ
ជំនឿសាសនាផ្សេងៗទៀតហើយនិង
ទីកន្លែងដ៏ពិសិដ្ឋពីបុរាណកាលមក
នោះ បរិស្ថានសង្គមនឹងមានស្ថានភាព
ល្អដដែល។

**ដកស្រង់ពីមហាបរិនិព្វានសូត្រ**

# ជំនឿតាមបែបប្រពៃណីនិងវិទ្យាសាស្ត្រ

មិនមែនគ្រាន់តែជាទស្សនៈផ្សេងគ្នាលើពិភពលោកតែមួយនោះទេ ប៉ុន្តែវាជាការយល់ខុសពីពិភពលោកខ្លួនឯងៈ អ្វីទៅជាភាពជាក់ស្តែងរបស់ធម្មជាតិ អ្វីដែលមាន អ្វីដែលគ្មាន តើមនុស្សជាតិនិងធម្មជាតិទាក់ទងគ្នាយ៉ាងដូចម្តេច តើពិភពលោកមានដំណើរការយ៉ាងដូចម្តេច។ មិនមែនគ្រាន់តែជាទស្សនៈផ្សេងគ្នាទៅលើពិភពលោកតែមួយនោះទេ ប៉ុន្តែវាក៏ជាការយល់ខុសគ្នាអំពីពិភលោកខ្លួនឯងផងដែរថា៖ អ្វីទៅជាសេចក្តីពិតនៃធម្មជាតិ អ្វីទៅមានពិត អ្វីទៅមិនមានពិត តើមនុស្សជាតិនិងធម្មជាតិទាក់ទងគ្នាយ៉ាងដូចម្តេច ហើយតើពិភពលោកមានដំណើរការយ៉ាងដូចម្តេច។



# ជំនឿតាមបែបប្រពៃណីនិងវិទ្យាសាស្ត្រ



តើមនុស្សនិងអមនុស្ស (សត្វ វិញ្ញាណ) មានរូបរាងស្រដៀងគ្នាដែរឬទេ?

តើមនុស្សនិងអមនុស្ស (សត្វ វិញ្ញាណ) មានគំនិតដូចគ្នាដែរឬទេ?



កិន្នរី
(វត្តប្រាសាទបាគង សៀមរាប)

# ជំនឿតាមបែបប្រពៃណីនិងវិទ្យាសាស្ត្រ



| មនុស្សនិងអមនុស្ស | វិទ្យាសាស្ត្រ | ជំនឿតាមទំនៀមទំលាប់ |
| --- | --- | --- |
| រូបរាងស្រដៀងគ្នា | មែន | មិនមែន |
| គំនិត សតិ ឬវិញ្ញាណស្រដៀងគ្នា | មិនមែន | មែន |

នេះជួយយើងឲ្យយល់ពីមូលហេតុដែលចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងចំណេះដឹងតាមបែបទំនៀមទំលាប់គឺតែងតែមានលក្ខណៈខុសគ្នាស្រលះ។

មានលក្ខណៈខុសគ្នា ប៉ុន្តែមានលក្ខណៈពិតដូចគ្នានិងមានសារសំខាន់ដូចគ្នា។



កិន្នរី
(ព្រះបរមរាជវាំង)

# ជំនឿតាមបែបប្រពៃណីនៅប្រទេសកម្ពុជា

- ព្រះពុទ្ធសាសនាបានរួមរស់ជាមួយគ្នាដោយសហវិជ្ជមានជាមួយនឹងបែបបទនៃជំនឿដើម:
  - អារក្ខ (អ្នកតា)
  - ព្រលឹងវីរៈបុរស
  - ព្រលឹងបុព្វបុរស
  - ព្រះ ទេវតា
  - អាចមើលឃើញច្បាស់ពីភាពសុខដុមរមនា រវាងមនុស្សនិងធម្មជាតិ។
  - តែងតែផ្តល់ជាគុណប្រយោជន៍ចំពោះការអភិរក្សបរិស្ថាន
  - ពីធីបុណ្យរួមគ្នា រវាងពុទ្ធសាសនានិងជំនឿអរូបិយ (ឧទាហរណ៍នៅប្រទេសថៃឡង់ដ៏: គម្រោងអភិរក្សនៅតំបន់ការ៉ែន គឺពិធីបំបួសដើមឈើរបស់ចៅអធិការវត្តព្រះគ្រូ ពីតាក់ ណានថាឃុម



ការបួងសួងដល់អារក្ខភ្នំ មេរ៉ា(Mera)

# ជំនឿអរូបិយៈ
## អ្នកតាព្រៃភ្នំ

- រឿងនិទានអំពីទេវតា
- បម្រាមនៅក្នុងព្រៃទាក់ទងនឹងជំនឿអរូបិយ
- ចូលស្បៀ



Tree spirit pagoda, Alishan, Taiwan









# បម្រាមនៅក្នុងព្រៃទាក់ទងនឹងជំនឿអរូបិយ

- អ្នកតា
- អារក្ខ
- ខ្មោច ព្រាយ បីសាច
- ទេវតា/ ព្រះ (ព្រះក្នុងសាសនាព្រះពុទ្ធ)



# ផ្នែកទី៣- សត្វដ៏ពិសិដ្ឋ រុក្ខជាតិដ៏ពិសិដ្ឋ តំបន់ស័ក្តិសិទ្ធិ (កន្លែងស័ក្តិសិទ្ធិ)

- រុក្ខជាតិដ៏ពិសិដ្ឋ– ដើមឈើ ផ្កា
- ប្រភេទសត្វដ៏ពិសិដ្ឋ
- តំបន់ស័ក្តិសិទ្ធិ (កន្លែងស័ក្តិសិទ្ធិ)
- ប្រភេទសត្វមួយចំនួនដែលមានអត្ថន័យតាមបែបវប្បធម៌



# រុក្ខជាតិដ៏ពិសិដ្ឋ





- ផ្កាឈូកៈ ផ្កាឈូក ដែលលូតដុះចេញផុតពីទឹកល្អក់ ឬ ភក់ ត្រូវបានចាត់ទុកជានិមិត្តរូបនៃសត្វលោក ដែលបានរួចផុតពីលោភៈ ទោសៈ មោហៈ។
- ផ្កាឈូកជាជង្វាយសម្រាប់ពុទ្ធបូជា ដ៏មានប្រជាប្រិយភាពនៅក្នុងព្រះពុទ្ធសាសនា ជាពិសេសនៅក្នុងពិធីបុណ្យវិសាខបូជា។
- បុណ្យផ្កា ( ពិធីបុណ្យផ្កា ) ដែលជារឿងនិទានទាក់ទងនឹងស្តេចសេរីលង្កា



# រុក្ខជាតិដ៏ពិសិដ្ឋ៖
## ដើមឈើជាម្ចាស់នៃព្រៃនិងព្រះពុទ្ធប្បដិមា





ព្រះពុទ្ធសមណគោតមទ្រង់បានត្រាស់ដឹងនៅក្រោមដើមពោធិព្រឹក្ស

# រុក្ខជាតិដ៏ពិសិដ្ឋ៖

## ដើមឈើជាម្ចាស់នៃព្រៃ និងព្រះពុទ្ធប្បដិមា





ព្រះពុទ្ធតណ្ហង្ករៈបានត្រាស់ដឹងនៅក្រោមដើម Rukaththana

# រុក្ខជាតិដ៏ពិសិដ្ឋនៅក្នុងសាសនាព្រះពុទ្ធ





# រុក្ខជាតិដ៏ពិសិដ្ឋ៖
## ការគូរផែនទីរុក្ខជាតិដ៏ពិសិដ្ឋ



ដើមឈើដែលធ្លាប់ឲ្យម្លប់ដ៏ត្រជាក់ត្រឈៃដល់អ្នកសម្រាប់
អង្គុយលេង ឬដេកលេង តាមតម្រូវការ អ្នកមិនត្រូវហែកកាប់
មែកធាងវាចុះទេ អំពើព្រៃផ្សៃគ្មានត្រាប្រណីនឹងកើតឡើង។

(ជាតក ភាគទី៤)

តើនៅក្នុងតំបន់ដែលអ្នករស់នៅមានដើមឈើអ្វីខ្លះ៖

- ដើមឈើជាម្ចាស់នៃព្រៃ (ដើមឈើព្រះ)
- ដើមឈើដែលមានទាក់ទងនឹងការត្រាស់ដឹងរបស់ព្រះពុទ្ធ
- ដើមឈើជាកន្លែងសម្រាប់វិញ្ញាណស័ក្តិសិទ្ធ



# រុក្ខជាតិដ៏ពិសិដ្ឋ



ដើមតាត្រាវ Ironwood or Tembusu (*Fagraea fragrans*) – ដើមឈើជាម្ចាស់នៃព្រៃ

# សត្វដ៏ពិសិដ្ឋ



- សត្វពស់នាគរាជ (ស្តេចពស់)
- សត្វដំរី
- សត្វអណ្តើក
- សត្វផ្សោត
- ប្រភេទបក្សីមួយចំនួន
- សត្វផ្សេងៗទៀត?

# សត្វដ៏ពិសិដ្ឋ







# សត្វដ៏ពិសិដ្ឋ៖
## សត្វរស់នៅក្នុងធម្មជាតិ



ម្នាលខ្លាទាំងឡាយអើយ!

ចូរអ្នកវិលត្រឡប់ទៅកាន់ព្រៃរបស់អ្នកវិញ។

ហើយចូរអ្នកកុំធ្វើឲ្យព្រៃនោះ ក្លាយទៅជាវាលល្ហល្ហេវ ដូច្នោះ ព្រោះថាបើគ្មានអ្នកទេ ព្រៃឈើមុខតែនឹងត្រូវគេកាប់រលំឲ្យរាបជាមិនខាន។

បើគ្មានព្រៃឈើ អ្នកមុខតែគ្មានទីជម្រកជារៀងរហូតទៅ។

**(ជាតកភាគទី៤)**

# សត្វដ៏ពិសិដ្ឋ
## សត្វដំរី





ព្រះពោធិសត្វ (អនាគតនឹងបានត្រាស់ដឹងជាព្រះពុទ្ធ) បានយាងចូលទៅកាន់ព្រះគភ៌ព្រះមាតារបស់ព្រះអង្គ គឺព្រះនាង សិរីមហាមាយាស្ថិតក្នុងរូបរាងជាដំរីស។

# សត្វដ៏ពិសិដ្ឋ៖
## សត្វដំរី





រឿងនិទានរបស់ដំរីដ៏ល្បីល្បាញមួយផ្សេងទៀតដកស្រង់ចេញពីវិន័យបិដក (ដំរីទេវទត្ត) មានជាប់ទាក់ទងនឹង ទេវទត្ត ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់។

# សត្វដ៏ពិសិដ្ឋ៖
## សត្វអណ្តើក

- រឿងកូរសមុទ្រទឹកដោះ ព្រះវិស្ណុនិម្មិតកាយ (ក្រឡាខ្លួន) ជាសត្វអណ្តើកមួយយ៉ាងធំឈ្មោះ "កុមិ" ជួយទ្រភ្នំមន្ទរៈឲ្យខ្ពស់ឡើងមកលើផ្ទៃទឹក។
- សត្វអណ្តើកជានិមិត្តរូបនៃ អាយុយឺនយូរនិងសេចក្តីចម្រុងចម្រើន។
- ប្រាសាទអង្គរវត្តឧទ្ទិសចំពោះព្រះក្នុងព្រហ្មញ្ញសាសនា (ព្រះវិស្ណុ ឬ ព្រះនារាយណ៍ )
- សត្វអណ្តើក=កស្សបៈ(ភាសាសំស្ក្រឹត)

ជាជូនតានៃសត្វមានជីវិតទាំងអស់។





# សត្វពិសិដ្ឋ
## សត្វអណ្តើក


ប្រាសាទភ្នំដា ប្រទេសកម្ពុជា


បដិមាសត្វអណ្តើកនៅស្រះស្រង់ ប្រទេសកម្ពុជា

# សត្វដ៏ពិសិដ្ឋ៖
## ប្រភេទត្រីមួយចំនួន



CRYSTAL BOWL FOUND IN BUDDHA'S TOMB.



FOOTPRINT OF THE BUDDHA.














# God's fishes: religion, culture and freshwater fish conservation in India

Published online by Cambridge University Press: **28 September 2015**

Nishikant Gupta, Arun Kanagavel, Parineeta Dandekar, Neelesh Dahanukar, Kuppusamy Sivakumar, Vinod B. Mathur and Rajeev Raghavan

Show author details

# សត្វដ៏ពិសិដ្ឋ៖

## សត្វផ្សោត



# សត្វដ៏ពិសិដ្ឋ៖
## ប្រភេទបក្សីមួយចំនួន

- សត្វកេងកង
- សត្វខ្លែងស្រាក
- សត្វផ្សេងទៀត ?





# សត្វដ៏ពិសិដ្ឋ៖
## សត្វផ្សេងទៀត?

- ប្រើស (សុវណ្ណសាមជាតក)
- ឈ្លូស
- សត្វផ្សេងទៀត?





# តំបន់ធម្មជាតិដ៏ស័ក្តិសិទ្ធិ

- ទីកន្លែងដែលជាប់ទាក់ទងនឹងប្រវត្តិដូនតា
- ទីតាំងវត្តអារាមនានា
- វិសាលភាពនៃជំនឿអរូបិយៈ វិញ្ញាណការពារភ្នំ ថ្ម ស្ទឹង ទន្លេ បឹង


Haling-Halang Mountain

# ទីកន្លែងដែលជាប់ទាក់ទងនឹងប្រវត្តិដូនតា- តំបន់អង្គរ (ខេត្តសៀមរាប)

- ប្រាសាទអង្គវត្ត- តារាជ តាពេជ្រ
- អង្គរធំ (អតីតរាជធានីយសោធរ)- ព្រះអង្គគោកធ្លក ព្រះវិហារ ៧ល្វេង
- ភ្នំគូលែន (រាជធានីដំបូងសម័យមហានគរ ស.វ ទី ៩)- ព្រះអង្គធំ
- ព្រះអង្គចេក ព្រះអង្គចម យាយទេព



# ប្រាសាទអង្គវត្ត- តារាជ តាពេជ្រ





# អង្គរធំ (អតីតរាជធានីយសោធរ)- ព្រះអង្គគោកធ្លក ព្រះវិហារ ៧ល្វែង





# ភ្នំគូលែន( រាជធានីដំបូងសម័យមហានគរ ស.វ ទី ៩ )- ព្រះអង្គធំ





# ព្រះអង្គចេក ព្រះអង្គចម យាយទេព





# ភ្នំក្រាំងមាស តំបន់វាលស្មៅ វាលធំ ឧទ្យានជាតិវីរជ័យ



# ទឹក

ផ្សោតរស់នៅក្នុងទន្លេអាយេយ៉ាវ៉ាឌី (Ayeyarwady) នៃប្រទេសភូមា។

តំបន់ព័ទ្ធជុំវិញទំហំ ១០០ហ្វីត (៣០.៤៨ម) នៅជិតវត្តអារាមក្បែរមាត់ទន្លេ ជាកន្លែងហាមឃាត់មិនឲ្យនេសាទ។



# សំណួរពិភាក្សា

- តើមានដើមឈើនិងប្រភេទសត្វណាខ្លះ ដែលមានអត្ថន័យបែបជំនឿអរូបិយនៅក្នុងសហគមន៍របស់អ្នក ហើយតើវាផ្តល់អត្ថប្រយោជន៍អ្វីខ្លះសម្រាប់សហគមន៍របស់អ្នក ?
- ហេតុអ្វីបានជាដើមឈើនិងប្រភេទសត្វទាំងនោះ មានសារៈសំខាន់ក្នុងព្រះពុទ្ធសាសនា ?
- តើអ្នកអាចបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃ ដើមឈើនិងសត្វទាំងនេះដល់សហគមន៍តាមវិធីណា ?

ឬ

- ពិភាក្សាអំពីតំបន់ធម្មជាតិដ៏ស័ក្តិសិទ្ធិ ដែលមាននៅក្បែរកន្លែងអ្នករស់នៅ។ តើតំបន់ស័ក្តិសិទ្ធិទាំងនោះមានសារៈសំខាន់ចំពោះសហគមន៍របស់អ្នកយ៉ាងដូចម្តេច ? តើត្រូវមានវិធានការអ្វីខ្លះដើម្បីថែរក្សាកន្លែងទាំងនោះ ?

# ប្រភេទសត្វមួយចំនួនដែលមានអត្ថន័យតាមបែបវប្បធម៌

សត្វនិងរុក្ខជាតិ ដែលជានិមិត្តរូបនៃប្រទេសកម្ពុជាៈ

- សត្វល្អូនតំណាងជាតិ នៃប្រទេសកម្ពុជា
- ថនិកសត្វតំណាងជាតិ នៃប្រទេសកម្ពុជា
- បក្សីសត្វតំណាងជាតិ នៃប្រទេសកម្ពុជា
- មច្ឆាតំណាងជាតិ នៃប្រទេសកម្ពុជា
- ផ្កាតំណាងជាតិ នៃប្រទេសកម្ពុជា
- ដើមឈើតំណាងជាតិ នៃប្រទេសកម្ពុជា
- ផ្លែឈើតំណាងជាតិ នៃប្រទេសកម្ពុជា



ឆ្នាំទី ៥ លេខ ១២ ថ្ងៃ ទី ៣១ ខែ មីនា ឆ្នាំ ២០០៥ រាជកិច្ច ទំព័រ ១៨៧០

ព្រះរាជក្រឹត្យ

ឆ្នាំទី ៥ លេខ ១២ ថ្ងៃ ទី ៣១ ខែ មីនា ឆ្នាំ ២០០៥ រាជកិច្ច ទំព័រ ១៨៧១

ត្រាស់បង្គាប់

មាត្រា ១.-

ព្រះរាជក្រឹត្យនេះ មានគោលបំណងកំណត់ឈ្មោះសត្វ និង រុក្ខជាតិ ដែលមានអត្ថិភាព និង សារប្រយោជន៍ពិសេស សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញនូវមរតកធម្មជាតិដ៏មានតម្លៃ និង លើកតម្កើងនូវមោទនភាពជាតិ ។

មាត្រា ២.-

សត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា មានឈ្មោះទៅតាមប្រភេទដូចខាងក្រោម :

១- ប្រភេទសត្វចតុប្បាទ : សត្វគោព្រៃ
២- ប្រភេទបក្សី : សត្វត្រយ៉ង
៣- ប្រភេទឧរង្គសត្វ : អណ្តើកសរសៃ (អណ្តើកហ្លួង)
៤- ប្រភេទមច្ឆា : ត្រីគល់រាំង
៥- ប្រភេទរុក្ខជាតិ : ដើមត្នោត
៦- ប្រភេទផ្កា : ផ្ការំដួល
៧- ប្រភេទផ្លែឈើ : ផ្លែចេកពងមាន់

# សាកល្បងរកចម្លើយ៖
## មកស្គាល់ពី ប្រភេទសត្វនិងរុក្ខជាតិ ដែលជានិមិត្តរូបជាតិរបស់អ្នក!



# សត្វល្មូនតំណាងជាតិ

?

# សត្វល្មូនតំណាងជាតិ៖
## អណ្តើកហ្លួង ឬ អណ្តើកសរសៃ



# ថនិកសត្វតំណាងជាតិ

?

# ថនិកសត្វតំណាងជាតិ៖
## គោព្រៃ



# បក្សីសត្វតំណាងជាតិ

?

# បក្សីសត្វតំណាងជាតិ៖

## ត្រយងយក្ស ( GIANT IBIS )



# មច្ឆាតំណាងជាតិ

?

# មច្ឆាតំណាងជាតិ៖
## ត្រីគល់រាំង ត្រីកាហោ ឬ ត្រីក្បាលឡាន



# ផ្កាតំណាងជាតិ

?

# ផ្កាតំណាងជាតិ៖
## ផ្ការំដួល



# ដើមឈើតំណាងជាតិ

?

# ដើមឈើតំណាងជាតិ៖
## ដើមត្នោត



# សំនួរបន្ថែមទៀតៈ
# ផ្លែឈើតំណាងជាតិរបស់កម្ពុជា

?

# ផ្លែឈើតំណាងជាតិរបស់កម្ពុជា៖
## ចេកពងមាន់



# ផ្នែកទី៤៖ ការអភិវឌ្ឍន៍នៅកម្ពុជាដើម្បីឲ្យសត្វមានជីវិតទាំងអស់បានគង់វង្សនិងឋិតថេរ

- ការអភិរក្ស
- ការប្រព្រឹត្តិចំពោះសត្វ ការប្រព្រឹត្តិចំពោះរុក្ខជាតិ
- ការការពារធនធានធម្មជាតិ (ទឹក ដី ខ្យល់ ធម្មជាតិ)
- ការបំពុលបរិស្ថាន



# ការអភិរក្ស
## បរិស្ថាន

- ពាក្យខ្មែរថា " បរិស្ថាន ឬ បរិដ្ឋាន "  មានដើមកំណើតមកពីពាក្យបាលី "បរិត្ត" ដែលមានន័យថា "ការការពារ ឬ ការគាំពារ"។
- តំបន់ដែលយើងកំពុងរស់នៅ គឺអាស៊ីអាគ្នេយ៍ដីគោកមានឈ្មោះម្យ៉ាងទៀតថា សុវណ្ណភូមិ ឬ "ទឹកដីមាស" ក្នុងភាសាបាលី។
- ដើមឈើដែលវ័យចំណាស់និងធ្វើសក្ការៈពីសំណាក់ពុទ្ធសាសនិកជន មានឈ្មោះថា "វនប្បតិ" ជាភាសាបាលីប្រែមកថា "ដើមឈើជាម្ចាស់នៃព្រៃ"។



The rubbed text of the recently discovered inscription in Cambodia dated to 7th century.



The term "Suvarnabhumi" as mentioned in a newly found 7th century Sanskrit inscription from Cambodia.

The inscription translated as:

*"....The great King Isanavarman is full of glory and bravery. He is the King of Kings who rules over **Suvarnabhumi** until the sea, which is the border, while the kings in the neighboring states honor his order to their heads...."*

# ការអភិវឌ្ឍ
## បរិស្ថាន

- ឈ្មោះជាភាសាបាលីរបស់ខេត្តនិងស្រុកជាច្រើននៅប្រទេសកម្ពុជា បានធ្វើឲ្យយើងនឹកឃើញដល់លក្ខណៈពិសេសរបស់ធម្មជាតិ ឬ វប្បធម៌នៃតំបន់ពិសេសៗទាំងនោះ។
  - រតនគិរី មានន័យថា "បព៌ត" ឬ "ភ្នំត្បូង"។
  - មណ្ឌលគីរី ជាពាក្យបាលី មានន័យថា "ហ៊ុំព័ទ្ធដោយថ្ម ឬ ភ្នំ"។
  - សម្បូណ៌ មកពីពាក្យបាលីថា សម្ពុរៈ មានន័យថា "ពេញប្រៀប ពោរពេញ" ឬ "គ្រាស់ក្រៃលច្រើន"។
  - ពោធិសាត់ ពាក្យ "ពោធិសត្វ" មានជាប់ទាក់ទងនឹងរឿងតំណាលមួយថា មានដើមពោធិ៍មួយដើមបានអណ្តែតបញ្ច្រាសទឹកហើយមកទើរនៅលើទីមួយ រួចត្រូវបានគេស្រង់យកទៅដាំនៅកន្លែងមួយដោយឲ្យឈ្មោះថា " ពោធិសោត់" ក្រោយមកទៀតគេនិយាយខ្លីថា "ពោធិសត់" រហូតមកដល់សព្វថ្ងៃ។

# ការប្រព្រឹត្តិចំពោះសត្វ

សពសត្វទាំងអស់ដែលបានកើតឡើងហើយ ជានិច្ចកាលរមែងតែងតែត្រូវការនូវសេចក្ដីសុខ និងអំពើល្អ ជាពិតប្រាកដ បុគ្គលទាំងឡាយណាដែលស្វះស្វែងរកសេចក្ដីសុខ ដោយការបៀតបៀនបុគ្គលដទៃ ដោយអំណាចឥទ្ធិពលរបស់ខ្លួន បុគ្គលទាំងឡាយនោះ លះបង់លោកនេះទៅនឹងមិនសម្រេចបាននូវសេចក្ដីសុខពិតប្រាកដឡើយ។

សពសត្វទាំងអស់ដែលបានកើតឡើងហើយ រមែងតែងតែប្រាថ្នាចង់បានសេចក្ដីសុខ បុគ្គលទាំងឡាយណាដែលស្វែងរកសេចក្ដីសុខ ដោយប្រាសចាកការបៀតបៀនបុគ្គលទាំងឡាយដទៃ តាមអំណាចឥទ្ធិពលរបស់ខ្លួន បុគ្គលទាំងនោះលះបង់លោកនេះហើយ នឹងបានសម្រេចនូវសេចក្ដីសុខពិតប្រាកដ។

**ទស្សនព្រះពុទ្ធ** (ដកស្រង់ពីគម្ពីរធម្មបទ- សុខវគ្គ)



# ការប្រព្រឹត្តិចំពោះរុក្ខជាតិ



ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រៀនប្រដៅថា គេមិនគប្បីបំផ្លាញជីវិតរុក្ខជាតិទ្បើយ។ នៅក្នុងវិន័យរបស់បព្វជិត ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ដាក់បញ្ញាតិយ៉ាងតឹងតែងនៅក្នុងគម្ពីរអង្គុត្តរនិកាយថា ភិក្ខុទាំងឡាយមិនត្រូវធ្វើឲ្យរបួសដល់ជីវិតរុក្ខជាតិតាមរបៀប ឬ រូបភាពណាមួយក៏ដោយ។

បុគ្គលណាមួយដែលចៀសវាងរួចអំពីការធ្វើឲ្យរបួសគ្រោះថ្នាក់ដល់ជីវិតគ្រាប់ពូជនិងរុក្ខជាតិ...... លះបង់ចោលនូវសេចក្ដីសៅហ្មង ដែលកើតអំពីបំណងអាក្រក់ ប្រកបដោយចិត្តរួចផុតពីបំណងអាក្រក់ បុគ្គលនោះនឹងរស់នៅដោយមានការគោរពចំពោះ សុខុមាលភាពនិងមានអារម្មណ៍ប្រកបដោយមេត្តាករុណាចំពោះគ្រប់ភាវៈដែលមានជីវិតទាំងអស់ បុគ្គលនោះមានឈ្មោះថាបានសំអាតនូវចិត្តរបស់ខ្លួន ដែលសៅហ្មងដោយបំណងអាក្រក់។

**ដកស្រង់ពីគម្ពីរ អង្គុត្តរនិកាយ**

# ការប្រមូលផល ឬ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព



ព្រះសម្មាសម្ពុទ្ធទ្រង់
បានប្រៀនប្រដៅថាៈ
គួរគិតដល់អ្វីដែលអ្នក
គួរយកពីព្រៃឈើ។





# ការការពារធនធានធម្មជាតិ (ទឹក ដី ខ្យល់ ធម្មជាតិ)

ដូចជាសត្វឃ្មុំ មិនធ្វើឲ្យមានការខូចខាតដល់ផ្កា ពណ៌ សម្បុរនិងក្លិន របស់ផ្កាឡើយ។ វាក្រេបតែទឹកដមផ្កា ប៉ុណ្ណោះឯង រួចវាហើរទៅបាត់។

យ៉ាងណាមិញ បណ្ឌិតទាំងឡាយជាអ្នកប្រាជ្ញគប្បី ត្រាច់ចរទៅក្នុងភូមិ ស្រុក ក៏ដូច្នោះដែរ។

**ដកស្រង់ពីធម្មបទដ្ឋកថា**






# ការប្រើប្រាស់ភាវៈរស់មានវិញ្ញាណ (សត្វ) និងភាវៈរស់គ្មានវិញ្ញាណ (រុក្ខជាតិ) ពីក្នុងព្រៃ





- ការប៉ងប្រាថ្នារបស់ព្រះពុទ្ធចំពោះភិក្ខុសង្ឃទាំងឡាយឲ្យចេះរស់នៅយ៉ាងសាមញ្ញ ចេះសន្សំសំចៃនិងចេះរស់នៅស្របទៅតាមធម្មជាតិ។
  **(ដកស្រង់ពី ចត្តាលោនិស្សយធម្មា)**
- តើមានធនធានអ្វីខ្លះនៅក្នុងសហគមន៍របស់អ្នក ត្រូវបានគេប្រើប្រាស់ដើម្បីបំពេញតម្រូវការក្នុងមូលដ្ឋាន ?
- តើការប្រមូលផល ឬ ការបរបាញ់បែបនោះ នៅក្នុងសហគមន៍របស់អ្នកមាននិរន្តរភាពដែរឬទេ ?
- ចូរពីភាក្សាអំពីវិធី ធ្វើយ៉ាងណាទើបការប្រមូលផល ការបរបាញ់និងការគ្រប់គ្រងព្រៃឈើ មានលក្ខណៈប្រសើរឡើង។

# ការចាប់សត្វ ការបរបាញ់និងការនេសាទ

គិតគូរពិចារណាអំពីវិធីប្រមាញ់សត្វខុសៗគ្នា៖



- អង្គប់
- សំណាញ់ មង ឬ អួន
- ការនេសាទ ដោយប្រើឧបករណ៍ឆក់ត្រី
- ថ្នាំពុល
- កាំភ្លើង
- ធ្នូ ស្នានិងព្រួញ
- គ្រឿងផ្ទុះ
- ផ្លែប្រមាញ់
- ចំពាមកៅស៊ូ
- អន្ទាក់



# ការបំពុល (បរិស្ថាន)

- ព្រះសម្មាសម្ពុទ្ធ ទ្រង់បានដាក់បទបញ្ញត្តិហាមប្រាមអំពីការធ្វើឲ្យទឹក ឬ ប្រភពទឹកកខ្វក់ ឬ ប្រភពទឹកពុល។
- ពុទ្ធបញ្ញាតិជាច្រើនដែលមាននៅក្នុងវិន័យបិដក បានហាមប្រាមដល់ភិក្ខុសង្ឃទាំងឡាយ មិនឲ្យបំពុលដីនិងទឹក ដោយការស្តោះទឹកមាត់ បន្ទោបង់លាមកនិងទឹកមូត្រឡើយ។
- តម្រងទឹកជាបរិក្ខារប្រើប្រាស់មួយ នៅក្នុងចំណោមបរិក្ខារប្រើប្រាស់ជាមូលដ្ឋានរបស់ភិក្ខុសង្ឃទាំងប្រាំបីប្រការ ដែលត្រូវគេផ្គត់ផ្គង់ឲ្យ នៅពេលសាងព្រះផ្នួសម្តងៗ។ សព្វថ្ងៃនេះ ភិក្ខុទាំងឡាយនៅតែទទួលយកប្រដាប់ច្រោះទឹកមកប្រើ ទុកជាគ្រឿងក្រើនរំលឹក ដើម្បីឲ្យធានតែទឹកស្អាតនិងការពារកុំឲ្យមានគ្រោះថ្នាក់ដល់សត្វល្អិតនិងសត្វមានជីវិតផ្សេងៗទៀត ដែលរស់នៅក្នុងទឹក។

ស្ទឹងមួយស្ថិតនៅក្នុងឃុំរាម ខេត្តព្រះសីហនុ
(ឆ្នាំ២០១៤)



# ការកែច្នៃជាថ្មីឡើងវិញ

ព្រះមហាអានន្ទ ជាឧបដ្ឋាកៈរបស់ព្រះពុទ្ធជាម្ចាស់ បានធ្វើការពិភាក្សាមួយជាមួយស្ដេចឧទេនរាជ។ នៅពេលនោះ បរិពារចំនួន ៥០០នាក់ របស់ស្ដេចឧទេន បានទៅកាន់សំណាក់ព្រះ អានន្ទ ដើម្បីស្ដាប់ព្រះធម៌ដែរ។ ដោយមានសេចក្ដីសប្បាយរីករាយជ្រះថ្លាជាមួយពាក្យប្រៀនប្រដៅរបស់ព្រះ អានន្ទ នោះ បរិពារទាំង ៥០០ នាក់ ក៏បានប្រគេនចីពរចំនួន ៥០០ ក្រេ ដល់ព្រះភិក្ខុអង្គនោះ។



# ការកែច្នៃជាថ្មីឡើងវិញ

ភ្ញាក់ផ្អើលនឹងព្រឹត្តិការណ៍បែបនេះ ព្រះរាជាអង្គនោះបានចូលទៅកាន់ព្រះ អានន្ទ ហើយបានទូលសួរថាៈ

**ព្រះរាជា៖** តើព្រះតេជព្រះគុណនឹងធ្វើអ្វីខ្លះជាមួយនឹងស្បង់ចីពរដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ ? តើព្រះតេជព្រះគុណបម្រុងនឹងបើកហាងលក់ស្បង់ចីពរទាំងអស់នេះមែនដែរឬទេ ?

**ព្រះមហាអានន្ទ៖** អាត្មាភាពនឹងចែករំលែកស្បង់ចីពរទាំងនេះ ប្រគេនដល់ភិក្ខុទាំងឡាយដទៃទៀត។

**ព្រះរាជា៖** តើភិក្ខុសង្ឃទាំងនោះនឹងយកស្បង់ចីពរចាស់ៗទាំងនោះ ទៅធ្វើអ្វីដែរ ?

**ព្រះមហាអានន្ទ៖** កាលណាគេទទួលបានស្បង់ចីពរថ្មី ស្បង់ចីពរចាស់ត្រូវគេយកទៅប្រើប្រាស់ជាកម្រាលពូក បើកម្រាលពូកនោះចាស់ទៅ ត្រូវយកទៅប្រើជាស្រោមពូក ហើយបើស្រោមពូកចាស់ទៅ ត្រូវយកទៅប្រើជាកម្រាលព្រំទៀត លុះកម្រាលព្រំចាស់ទៅ ត្រូវយកទៅប្រើជាក្រណាត់ពោសជូតធូលី ហើយបើក្រណាត់ជូតធូលីនោះចាស់ទៅ គេយកទៅប្រើជាក្រណាត់ជូតជើង ហើយបើក្រណាត់ជូតជើងនេះចាស់រហែករយីរយៃទៅនោះ នៅទីបំផុត គេត្រូវយកវាមកច្របាច់លុញជាមួយដីឥដ្ឋ ដើម្បីប្រើសម្រាប់ជួសជុលក្តារក្រាលនិងជញ្ជាំងដែលប្រហោង ឬ ប្រេះបែក។ **ព្រះវិន័យបិដក** ( ភាគ២ )

# ផ្នែកទី៥៖ គំរូនៃការអភិរក្សដោយផ្អែកលើព្រះពុទ្ធសាសនា

- ធម្មយាត្រា
- ព្រៃឈើសហគមន៍
- ការបំបួសដើមឈើ
- ការល្បាតព្រៃដោយផ្អែកលើព្រះពុទ្ធសាសនា
- ការព្យាបាលដំបៅផែនដីនិងឋានប្រព័ន្ធ
- ការអប់រំបរិស្ថាន



# ធម្មយាត្រា



- ធម្មយាត្រា ដែលមានន័យថា "ការត្រាច់ចរដើម្បីស្វែងរកសច្ចភាព"
- សម្ដេចព្រះមហាឃោសានន្ទជាអ្នកជម្រុញលើកទឹកចិត្តឲ្យមានការធ្វើធម្មយាត្រានេះឡើង។
- កូនពោធិព្រឹក្សជាច្រើនដើម ដែលជាអំណោយពីប្រទេសស្រីលង្កា ត្រូវបានគេយកមកដាំ នៅក្នុងរយៈពេលនៃការធ្វើធម្មយាត្រាចាប់ពីឆ្នាំ ១៩៩២ មក។

# ធម្មយាត្រា

កាលណាយើងស្រឡាញ់ការពារបរិស្ថាន កាលនោះធម្មជាតិមុខតែល្អចំពោះយើងហើយ។

ដើមឈើទាំងឡាយប្រៀបឧបមាដូចជាមាតាបិតារបស់យើងដូច្នេះដែរ។ ដើមឈើចិញ្ចឹមបីបាច់ថែរក្សាយើងឲ្យធំធាត់ ផ្តត់ផ្គង់ដល់យើងនូវវត្ថុគ្រប់បែបយ៉ាង មានដូចជាផ្លែ ស្លឹក មែក ដើម ជាដើម។ ដើមឈើទាំងនោះផ្តល់ដល់យើងនូវម្ហូបអាហារនិងបំពេញបំណងប្រាថ្នារបស់យើងជាច្រើនទៀត។ ប៉ុន្តែបើយើងកាប់រំលំដើមឈើចោល វានឹងមិនមានភ្លៀងតទៅទៀតទេ។ ដើមឈើធ្វើឲ្យមានភ្លៀងធ្លាក់។

អាស្រ័យហេតុនេះហើយ នៅក្នុងការធ្វើធម្មយាត្រានេះ យើងនឹងផ្សព្វផ្សាយព្រះធម៌អំពីការថែរក្សាការពារខ្លួនយើងនិងការថែរក្សាការពារបរិស្ថានរបស់យើង ដែលនេះជាព្រះធម៌ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើងទាំងអស់គ្នា។

**សម្ដេចព្រះមហាឃោសានន្ទ**

# ព្រៃឈើសហគមន៍

- បញ្ញត្តិនៃស័ព្ទ "ព្រៃឈើសហគមន៍" បានទៅជាផ្នែកមួយនៃពុទ្ធប្បវេណីជាយូរអង្វែងណាស់មកហើយ។
- ព្រៃឈើសហគមន៍បានទទួលការអភិវឌ្ឍឡើង នៅពេលដែលមហាជននៅមូលដ្ឋានយកចិត្តទុកដាក់ថែរក្សានិងគ្រប់គ្រងព្រៃឈើ ដែលពួកគេតែងតែពឹងអាស្រ័យ សម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។
- ព្រៃឈើសហគមន៍ក៏រួមមានទាំងការដាំដើមឈើឡើងវិញ នៅទីព្រៃឈើណាដែលទទួលការរេចរឹល។
- គម្រោងការនានានៃព្រៃឈើសហគមន៍ អាចផ្តួចផ្តើមគំនិតឡើងពីសំណាក់ព្រះសង្ឃតែម្តង (ព្រៃសង្ឃសហគមន៍រុក្ខារៃន)។
- ព្រះភិក្ខុ ញ៉ែម គឹមតេង បានបង្កើតអង្គការសន្តិសេនា នៅក្នុងខេត្តស្វាយរៀង ដើម្បីទទួលរ៉ាប់រងធ្វើការថែរក្សាការពារបរិស្ថាន។
- ព្រៃឈើសហគមន៍មួយកន្លែងគឺ ព្រៃចំការគគីរទី១ នៅក្នុងស្រុកច័ន្ទ្រា ខេត្តខេត្តស្វាយរៀង ត្រូវបានគេអភិវឌ្ឍឡើងដោយការប្រេបាច់បញ្ចូលគ្នា រវាងលទ្ធិព្រះពុទ្ធសាសនានិងជំនឿប្រពៃណីរបស់សហគមន៍ ដើម្បីការពារនិងដាំដើមឈើឡើងវិញ នៅតំបន់ព្រៃឈើនោះ។



វេស្សន្តរជាតក (ជំពូក១១)



# ព្រៃសង្ឃសហគមន៍រុក្ខាវ័ន



ការកំណត់ព្រំប្រទល់ព្រៃសហគមន៍ (ព្រៃសង្ឃសហគមន៍រុក្ខាវ័ន)



ព្រះតេជព្រះគុណ ប៊ុន សាលួត នៅខេត្តឧត្តរមានជ័យ (ព្រៃសង្ឃសហគមន៍រុក្ខាវ័ន)

# ការបំបួសដើមឈើ

កាលណាដើមឈើមួយដើមត្រូវបានយើងបំបួសរួចហើយ ដើមឈើនោះនឹងក្លាយជាព្រះសង្ឃ ហើយយើងប្រាប់ទៅមនុស្សផង ទាំងពួងថា កាលណាអ្នកណាហ៊ានកាប់ដើមឈើនោះប្រៀបដូចជាសម្លាប់ព្រះសង្ឃដូច្នោះដែរ។

**សម្តេចព្រះមហាឃោសានន្ទ**
(ក្នុងពិធីបំបួសដើមឈើនៅខេត្តរតនគិរី ជាការដាស់តឿនពីការកាប់បំផ្លាញព្រៃឈើ)



https://www.youtube.com/watch?v=5pk2f_0Ec9M



ព្រះសង្ឃនៅខេត្តឧត្តរមានជ័យ (ព្រៃសង្ឃសហគមន៍ក្តាវ៉ន)

# ការល្បាតព្រៃដោយផ្អែកលើព្រះពុទ្ធសាសនា៖
## ការសន្ទនាតាមធម៌ព្រះ ដោយមានការចូលរួម ដោយគ្មានអាវុធនិងអហិង្សា







ព្រះសង្ឃនៅខេត្តឧត្តរមានជ័យ (ព្រៃសង្ឃសហគមន៍រុក្ខាវ័ន)

# ការព្យាបាលជំងឺផែនដីនិងឋានព្រះ
## ការដាំដើមឈើ សួនឧទ្យាន

- ការធ្វើបុណ្យកុសលតាមរយៈអំណោយសួនឧទ្យាន ឬ ព្រៃព្រឹក្សា។
  ឧទាហរណ៍៖ ក្នុងសម័យព្រះពុទ្ធកាលនៅវត្តជេតពន (នគរកោសលៈ) មានសេដ្ឋីម្នាក់ឈ្មោះអនាថបិណ្ឌិក បានស្វែងរកទិញព្រៃដើម្បីកំសាន្តមួយកន្លែងពីព្រះអង្គម្ចាស់ឈ្មោះជេត ហើយយកទៅថ្វាយព្រះសម្មាសម្ពុទ្ធ។
- ពេលថ្មីៗនេះ វត្តចាស់ (ខេត្តកំពង់ចាម) បានដំណើរការបន្តធ្វើឡើងវិញលើទំហំដី ១០ហិកតា ឲ្យបានទៅជាសួនឧទ្យានសាធារណៈមួយ។

អ្នកដាំព្រៃឈើនិងដើមឈើហូបផ្លែ ព្រមទាំងអ្នកទាំងឡាយណា ដែលស្ថាបនាផ្លូវថ្នល់ ស្ពាន ទំនប់ទឹក ជីកអណ្តូងទឹកនិងស្ថាបនាសាលាធទាន ឲ្យទានទឹក អ្នកទាំងឡាយនោះមានឈ្មោះថាឲ្យនូវទីជម្រកដល់អ្នកដែលគ្មានផ្ទះសំបែងនោះដែរ កុសលកម្មនឹងកើតមានដល់បុគ្គលទាំងឡាយនោះគ្រប់ទិនទិវារាត្រីឥតបីឃ្លៀងឃ្លាតឡើយ។ ហើយដោយអំណាចនៃផល្លាអានិសង្ស ដែលកើតឡើងពីអំពើត្រឹមត្រូវនិងគុណធម៌បែបនេះ បុគ្គលនោះលុះចាកលោកទៅនឹងបានទៅកើតក្នុងស្ថានសួគ៌ជាមិនខានហោង។ **ឧសុវ្រុនព្រះពុទ្ធ** (ដកស្រង់ពីគម្ពីរសំយុត្តនិកាយ)



# ការអប់រំបរិស្ថាន

- តាមរយៈវត្តអារាម
- តាមរយៈសាលារៀន
- តាមរយៈពិធីបុណ្យផ្សេងៗ
- ការជួបប្រជុំនៅតាមសហគមន៍



# ផ្នែកទី៦- ការធ្វើផែនការសកម្មភាពរួមគ្នាមួយដោយមានការរួម

តើជំនឿរបស់អ្នក ការអនុវត្តនិងការប្រាព្ធពិធីបុណ្យផ្សេងៗ អាចជួយដល់ការការពារបរិស្ថាននៅក្នុងមូលដ្ឋានរបស់អ្នកបាន តាមវិធីណា ?

- ពិភាក្សាម្នាក់ឯង ឬ បង្កើតជាក្រុមតូចៗ ដោយជ្រើសរើសប្រធានបទ ១ ក្នុងចំណោមប្រធានបទជាច្រើនផ្សេងទៀត នៅក្នុងមេរៀននេះ។
- កត់ចំណាំអំពីមូលហេតុដែលទាក់ទាញការចាប់អារម្មណ៍របស់អ្នកនិងហេតុវិធីក្នុងការពិចារណា ដែលអ្នកអាចធ្វើការសង្កេតលើសកម្មភាពណាមួយ នៅក្នុងសហគមន៍របស់អ្នក។
- ពិភាក្សានិងរាយវិធីផ្សេងៗនៃការអនុវត្ត ដែលអាចជួយដល់ការការពារបរិស្ថានតាមរយៈវត្តអារាម ហើយសរសេរអំពីការអនុវត្តតាមរយៈព្រះពុទ្ធសាសនា ប្រពៃណីនិងពីធីបុណ្យផ្សេងៗ។
- ជ្រើសរើសយកសកម្មភាពទាំងឡាយណា ដែលសមស្របបំផុតសម្រាប់សហគមន៍របស់អ្នក។

# ផ្នែកទី៦- ការធ្វើផែនការសកម្មភាពរួមគ្នាមួយដោយមានការរួម

- សូមយកសកម្មភាពមួយណា ដែលអ្នកគិតថាអាចធ្វើបានក្នុងរយៈពេល ៦ ខែ។
- បង្កើតជាក្រុមពិភាក្សាធំមួយ  សរសេរផែនការសកម្មភាពរយៈពេល ៦ ខែ។ ចំណាំថ្ងៃបុណ្យតាមបែបព្រះពុទ្ធសាសនា ឬ ជំនឿតាមប្រពៃណីសំខាន់ៗនិងពិធីបុណ្យផ្សេងៗទៀត។
- សរសេរចំណាំ៖ ពីសប្តាហ៍មួយ ទៅសប្តាហ៍មួយទៀត ពីខែមួយទៅខែមួយទៀត ពេលដែលសកម្មភាពបរិស្ថានទាំងនោះនឹងអនុវត្តធ្វើឡើង។
  - តើសកម្មភាពនោះត្រូវចំណាយរយៈពេលប៉ុន្មាន?
  - តើអ្នកណាជាអ្នកទទួលខុសត្រូវអនុវត្ត?
  - តើសហគមន៍ចូលរួមអនុវត្តយ៉ាងដូចម្តេច?
  - លទ្ធផលរំពឹងទុក?



# APPENDIX: LITERATURE REFERENCES


Cry From The Forest (1999) - A Buddhism and Ecology Community Learning Tool. Published by the Buddhist Institute in cooperation with the NGO Working Group for Non-formal Monk Environmental Education Project (MEEP) and with the support of UNDP-ETAP in collaboration with UNESCO.

Gregory McCann and Yi-Chung Su (2016) Animism and traditional knowledge disappear in Virachey National Park, Cambodia, in Asian Sacred Natural Sites: Verschuuren, Furuta (eds.) Philosophy and Practice in Protected Areas and Conservation - Routledge

https://sacrednaturalsites.org/

https://www.scribd.com/document/12237057/Animals-and-Plants-as-National-Symbols-of-Cambodia

https://intocambodia.org

http://www.bl.uk/manuscripts/Viewer.aspx?ref=OR_14068_f001r

https://scroll.in/article/824513/harmony-serenity-watchfulness-what-the-deer-signifies-in-thai-manuscripts-on-buddhas-birth-tales

https://www.khmertimeskh.com/50865828/great-hornbills-spotted-in-phnom-penh-may-be-a-good-sign/

https://www.bibhudevmisra.com/2016/11/the-turtle-supporting-mount-meru-in.html

http://www.arcworld.org/downloads/the%20assisi%20declarations.pdf

https://britishlibrary.typepad.co.uk/asian-and-african/cambodia/

# APPENDIX: LITERATURE REFERENCES


https://www.bbc.co.uk/bitesize/guides/z4b42hv/revision/3

https://www.dailynews.lk/2019/11/12/features/202581/sacred-trees-buddhism

https://www.sunnataram.org/dhamma-teachings/buddhist-environmental-ethics

https://blogs.bl.uk/asian-and-african/2015/06/28-buddhas.html

https://intocambodia.org

https://commons.wikimedia.org/wiki/File:Gautama_Buddha_gains_nirvana.jpg

https://commons.wikimedia.org/wiki/File:March_To_The_Arang_Valley_(51495170).jpeg

https://commons.wikimedia.org/wiki/File:Dhammayietra_for_Lampatao_River_Basin_2010.jpg

https://commons.wikimedia.org/wiki/File:XRF-krasue.jpg

https://commons.wikimedia.org/wiki/File:Mrenh_Gongveal_house.jpg

https://commons.wikimedia.org/wiki/File:Kreung_banana_spirit.jpg

https://commons.wikimedia.org/wiki/File:Prey_Lang_Forest_Aerial.jpg

https://commons.wikimedia.org/wiki/File:Bodhgaya_3639641913_f4c5f73689_t.jpg)

# ឧបសម្ព័ន្ធ៖ សិទ្ធិលើរូបភាព

គំនូរនៅក្របមុខ និងក្រោយ គូរដោយ © ម៉ារៀ ចារ៉ា ផារ៉ូលីន។

រូបភាពស្ទើរតែទាំងអស់រក្សាសិទ្ធិដោយ ACCB លើកលែងតែរូបភាពមួយចំនួនដែលបានបញ្ជាក់ឈ្មោះអ្នកថតរូប ដូចមានរៀបរាប់ខាងក្រោមនេះ៖

| | | |
|---|---|---|
| ទំព័រ | ២ | Chanrasmey Miech (CC BY-SA 4.0) |
| ទំព័រ | ៤ | Public Domain (British Library) |
| ទំព័រ | ៧ | ឆ្វេងខាងលើ: unknown<br>កណ្ដាល: Buffalo Trails |
| ទំព័រ | ៩ | ACCB/ ឌីណា សុវណ្ណរតនៈ |
| ទំព័រ | ១០ | Luc Forsyth (CC BY 3.0) |
| ទំព័រ | ១១ | ACCB/ Daniel Roper-Jones |
| ទំព័រ | ១៣ | ឆ្វេង: Chanrasmey Miech (CC BY-SA 4.0)<br>ស្ដាំ: Christel Griffioen |
| ទំព័រ | ១៤ | Abigaël Pesses |
| ទំព័រ | ១៧ | ឆ្វេង: Jean-Pierre Dalbéra (CC BY 2.0) |
| ទំព័រ | ១៨ | Greg McCann (sacrednaturalsites.org) |
| ទំព័រ | ១៩ | Jpatokal (CC BY-SA 4.0) |
| ទំព័រ | ២០ | ឆ្វេងខាងលើ: EarthMonkeyCreative (CC BY 4.0)<br>ឆ្វេងខាងក្រោម: Franz Xaver (CC BY-SA 3.0)<br>កណ្ដាល: Xavier Romero-Frias (CC BY-SA 3.0)<br>ស្ដាំ: Jean-Pierre Dalbéra (CC BY 2.0) |
| ទំព័រ | ២១ | Willuconquer (CC BY-SA 4.0) |
| ទំព័រ | ២២ | Prey Lang Community Network (CC BY 2.5) |
| ទំព័រ | ២៣ | ស្ដាំខាងលើ: Scott Semans (CC BY 3.0)<br>ស្ដាំខាងក្រោម: Buffalo Trails |
| ទំព័រ | ២៤ | ឆ្វេង: Ken Wieland (CC BY-SA 2.0)<br>ស្ដាំ: Public Domain (British Library) |
| ទំព័រ | ២៥ | ឆ្វេង: [CC]: mauroguanandi<br>ស្ដាំ: Public Domain (British Library) |

# ឧបសម្ព័ន្ធ៖ សិទ្ធិលើរូបភាព

គំនូរនៅក្របមុខ និងក្រោយ គូរដោយ © ម៉ារៀ ចារ៉ ផារ៉ូលីន។

រូបភាពស្ទើរតែទាំងអស់រក្សាសិទ្ធិដោយ ACCB លើកលែងតែរូបភាពមួយចំនួនដែលបានបញ្ជាក់ឈ្មោះអ្នកថតរូប ដូចមានរៀបរាប់ខាងក្រោមនេះ៖

| | | |
|---|---|---|
| ទំព័រ | ២៦ | ឆ្វេង: Christophe95 ( CC BY-SA 4.0 )<br>ស្តាំ: Benvda ( CC BY-SA 3.0 ) |
| ទំព័រ | ២៧ | ឆ្វេង: កៃ ហាក់ឡី<br>ស្តាំ: Buffalo Trails |
| ទំព័រ | ២៨ | ឆ្វេង: Wouter Hagens ( public domain )<br>ស្តាំ: https://www.yosothor.org/publications/khmer-renaissance/chapter-two/cher-ta-trav.html |
| ទំព័រ | ៣០ | ឆ្វេង: ទៀ ម៉ៅ<br>កណ្តាល: Buffalo Trails |
| ទំព័រ | ៣២ | ស្តាំ: Buffalo Trails |
| ទំព័រ | ៣៤ | ឆ្វេង: Christel Griffioen<br>កណ្តាល: Ddalbiez ( CC BY-SA 3.0 )<br>ស្តាំ: WCS/ ល័ក្ខ រតនា |
| ទំព័រ | ៣៥ | មិនដឹងប្រភព |

| | | |
|---|---|---|
| ទំព័រ | ៣៦ | មិនដឹងប្រភព |
| ទំព័រ | ៣៧ | WWF-Cambodia |
| ទំព័រ | ៣៨ | ឆ្វេង: Sudharshan Kuselan ( inaturalists )<br>ស្តាំ: Buffalo Trails |
| ទំព័រ | ៣៩ | ឆ្វេងខាងក្រោម: មិនដឹងប្រភព |
| ទំព័រ | ៤០ | https://sacrednaturalsites.org/items/preserving-nature-and-culture-with-animistic-ecotourism-in-cambodia/ |
| ទំព័រ | ៤១ | ពេជ្រ សុភា |
| ទំព័រ | ៤២ | Buffalo Trails |
| ទំព័រ | ៤៣ | ពេជ្រ សុភា |
| ទំព័រ | ៤៤ | ពេជ្រ សុភា |
| ទំព័រ | ៤៥ | ជិម សុភាព |
| ទំព័រ | ៤៦ | https://sacrednaturalsites.org/items/preserving-nature-and-culture-with-animistic-ecotourism-in-cambodia/ |

# ឧបសម្ព័ន្ធ៖ សិទ្ធិលើរូបភាព

គំនូរនៅក្របមុខ និងក្រោយ គូរដោយ © ម៉ារៀ ចាវ៉ា ផារ៉ូលីន។

រូបភាពស្ទើរតែទាំងអស់រក្សាសិទ្ធិដោយ ACCB លើកលែងតែរូបភាពមួយចំនួនដែលបានបញ្ជាក់ឈ្មោះអ្នកថតរូប ដូចមានរៀបរាប់ខាងក្រោមនេះ៖

| | | |
|---|---|---|
| ទំព័រ | ៤៧ | មិនដឹងប្រភព |
| ទំព័រ | ៥០ | Albeiro Rodas ( Public domain ) |
| ទំព័រ | ៥២ | WCS/ Mengey Eng |
| ទំព័រ | ៥៤ | មិនដឹងប្រភព |
| ទំព័រ | ៥៦ | ACCB/ ភោគ សម្ផស្ស |
| ទំព័រ | ៥៨ | ePond.eu |
| ទំព័រ | ៦០ | មិនដឹងប្រភព |
| ទំព័រ | ៦២ | Buffalo Trails |
| ទំព័រ | ៦៤ | មិនដឹងប្រភព |
| ទំព័រ | ៦៥ | OSMOSE |
| ទំព័រ | ៦៦ | Joe165 ( CC BY-SA 4.0 ) |
| ទំព័រ | ៦៨ | www.lacma.org ( public domain ) |
| ទំព័រ | ៧០ | ឆ្វេង: Adam Jones ( CC BY-SA 2.0 )<br>កណ្ដាល និងស្ដាំ: Buffalo Trails |
| ទំព័រ | ៧១ | ឆ្វេង: Eric Guerin<br>ស្ដាំ: ពេជ្រ សុភា |
| ទំព័រ | ៧៣ | ឆ្វេង: Chris Graham/ AusAID ( CC BY 2.0 )<br>ស្ដាំ: OSMOSE |
| ទំព័រ | ៧៤ | Wikirictor ( CC BY-SA 4.0 ) |
| ទំព័រ | ៧៥ | Paingpeace ( CC BY-SA 4.0 ) |
| ទំព័រ | ៧៧ | www.arcworld.org ( ARC ) |
| ទំព័រ | ៧៨ | ណវ ( CC BY-SA 3.0 ) |
| ទំព័រ | ៨១ | Chantal Elkin |
| ទំព័រ | ៨២ | Chantal Elkin |
| ទំព័រ | ៨៣ | Chantal Elkin |
| ទំព័រ | ៨៤ | Isa Rohany |
| ទំព័រ | ៨៧ | Christian Pirkl ( CC BY-SA 4.0 ) |

អង្គការ WWF បម្រើការងារនៅជាង ១០០ប្រទេស ដើម្បីការកសាងអនាគតសម្រាប់ការរស់នៅប្រកបដោយភាពសុខដុមរមនារវាងមនុស្សជាមួយនឹងធម្មជាតិ។ ដោយសារតែសុខុមាលភាពរបស់មនុស្ស សត្វព្រៃនិងបរិស្ថានធម្មជាតិ ត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធទើបអង្គការ WWF អនុវត្តន៍តាមយុទ្ធសាស្ត្រសមាហរណកម្ម ដើម្បីឆ្ពោះទៅសម្រេចគោលដៅការងាររបស់ខ្លួន។ WWF ខិតខំថែរក្សា ការពារធម្មជាតិក្នុងពិភពលោក ជួយដល់ប្រជាជនឲ្យរស់នៅប្រកបដោយនិរន្តរភាពនិងចាត់វិធានការដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។

កម្មវិធីជំនឿនិងគុណតម្លៃ របស់ WWF ដែលបានឧបត្ថម្ភសៀវភៅមគ្គុទ្ទេសក៏នេះឡើង ដើម្បីកៀរគរឲ្យមានការចូលរួមពីថ្នាក់ដឹកនាំតាមមូលដ្ឋាននិងសហគមន៍តាមបែបបទជំនឿអរូបិយ សាសនានិងវប្បធម៌ ព្រមទាំងគុណប្រយោជន៍របស់ពួកគេ។

មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB) ត្រូវបានបង្កើតឡើងនិងប្រតិបត្តិការដោយសួនសត្វអាល់វិតធឿស្សូម៉ឺនស្ទឿ Allwetterzoo Munster។ ACCB គឺជាមជ្ឈមណ្ឌលអភិរក្សសត្វព្រៃមុនដំបូងគេបង្អស់មួយនៅប្រទេសកម្ពុជា ដែលមានទីតាំងនៅជើងភ្នំក្បាលស្ពាន ចម្ងាយប្រហែលជា ៥០គីឡូម៉ែត្រ ខាងជើងតំបន់អង្គរដែលជាបេតិកភណ្ឌពិភពលោកដ៏ល្បីល្បាញមួយទទួលស្គាល់ដោយអង្គការយូណេស្កូ។ ជារៀងរាល់ឆ្នាំ សត្វព្រៃរាប់រយក្បាលត្រូវបានស្តារនីតិសម្បទាហើយលែងត្រឡប់ទៅក្នុងព្រៃធម្មជាតិវិញ (ប្រសិនបើអាច)។ លើសពីនេះទៀត ACCB បានអនុវត្តសកម្មភាពអប់រំបរិស្ថានដើម្បីលើកកម្ពស់ការយល់ដឹងអំពីការគំរាមកំហែងនានាដែលប៉ះពាល់ដល់ប្រភេទសត្វព្រៃដែលរងគ្រោះជិតផុតពូជនៅប្រទេសកម្ពុជា។ សៀវភៅ **ជំនឿនិងគុណតម្លៃ៖ ទំនាក់ទំនងរវាងមនុស្សជាតិនិងធម្មជាតិ** នេះ ត្រូវបានរៀបចំឡើងដើម្បីគាំទ្រ ពង្រឹងសមត្ថភាពដល់ព្រះសង្ឃពុទ្ធសាសនាដែលបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការពារនិងអភិរក្សសត្វព្រៃនៅប្រទេសកម្ពុជា។